In August 2018, the World Health Organization announced in a rapid communication major changes to its recommendations for treating rifampicin-resistant and multidrug-resistant tuberculosis (RR-/MDR-TB), including the recommendation that most patients with DR-TB should be treated with fully oral treatment regimens. TAG will update this and other documents upon WHO's release of updated guidelines.

# ដឹងអំពីសិទ្ធិរបស់អ្នក

## ការបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺរបេង

## សិទ្ធិ និងការធ្វើរោគវិនិច្ឆ័យ

ដោយ GISA DANG

កែសំរួលដោយ Tsira Chakhaia, Brian Citro, Vivian Cox, Mike Frick, Jennifer Furin, Erica Lessem, Alexander William Mbuya, Lindsay McKenna, John Mdluli, Jane Rahedi Ong'ang'o, Hadija H. Semvua, and Zani de Wit



### តើខ្ញុំដឹងដោយរបៀបណា ថាខ្ញុំត្រូវការធ្វើតេស្តរកជំងឺរបេង ?

ប្រសិនបើអ្នកក្អកលើសពី ពីរសប្តាហ៍ ស្រកទម្ងន់ ក្អកចេញឈាម ឬចេញញើសពេលយប់ អ្នកគួរតែធ្វើតេស្តរកជំងឺរបេង។ប្រសិនបើអ្នកមានផ្ទុកមេរោគអេដស៍ អ្នកគួរតែត្រូវបានធ្វើតេស្តជាទៀងទាត់រកជំងឺរបេង។ ដំបូងអ្នកអាចត្រូវបានគេសួរអំពីរោគសញ្ញាទាំងនេះ ឬតម្រូវអោយថតដោយកាំរស្មី X-ray ។ ការធ្វើបែបនេះ អាចផ្តល់ព័ត៌មានអំពីថាតើអ្នកត្រូវការធ្វើតេស្តរកជំងឺរបេងដែរឬទេ។ កាំរស្មី X-ray មិនមែនជាការធ្វើតេស្តជំងឺរបេងដោយខ្លួនឯងទេ ព្រោះមានអ្វីៗជាច្រើនដែលមិនមែនជាជំងឺរបេង អាចមើលទៅដូចជំងឺរបេងនៅលើកាំរស្មី X-ray ដូចនេះតម្រូវឱ្យមានការធ្វើតេស្តជំងឺរបេងជាក់លាក់បន្ថែមទៀត ប្រសិនបើសង្ស័យថាអ្នកមានជំងឺរបេង ដែលថតចេញពីកាំរស្មី X-ray ។

### តើជំងឺរបេងគួរតែត្រូវបានគេធ្វើរោគវិនិច្ឆ័យដូចម្តេច ?

អ្នកដែលកំពុងធ្វើតេស្តរកជំងឺរបេងគួរតែមានសិទ្ធិចូលទៅ GeneXpert MTB / RIF ឬ GeneXpert MTB /RIF Ultra ជាការធ្វើតេស្តដំបូង (ជួនកាលគេហៅថាតេស្ត CBNAAT) ។ GeneXpert អាចផ្តល់លទ្ធផលបានលឿន និងមានភាពត្រឹមត្រូវជាងការធ្វើតេស្តកំហាកតាមមីក្រូស្កុបធម្មតា។ នេះគឺជាការពិតសម្រាប់មនុស្សពេញវ័យ និងកុមារនិងសម្រាប់មនុស្សរស់នៅជាមួយមេរោគអេដស៍។ ប្រសិនបើ GeneXpert មិនរកឃើញជំងឺរបេងទេ ប៉ុន្តែអ្នក ឬអ្នកថែទាំសុខភាពរបស់អ្នកកំពុងតែព្រួយបារម្ភថាអ្នកមានជំងឺរបេង អ្នកមានសិទ្ធិធ្វើតេស្តរោគវិនិច្ឆ័យបន្ថែមទៀតបាន។ GeneXpert គួរតែ មិនមែនជាការធ្វើតេស្តដំបូងបំផុតនៃជំងឺរបេងទេ នៅពេលនរណាម្នាក់ក្លាយជាអ្នកមានជំងឺធ្ងន់ធ្ងរ និងមានមេរោគអេដស៍។ ដូច្នេះទាំងការធ្វើតេស្តទៅលើទឹកនោមដោយ LAM និង GeneXpert នឹងត្រូវយកមកប្រើ សូមមើលរូបខាងក្រោម

ទោះបីជា GeneXpert ជាឧបករណ៍ធ្វើតេស្តដំបូងគេ តែនៅកន្លែងជាច្រើននៅតែប្រើប្រាស់មីក្រូស្កុបជាការធ្វើតេស្តដំបូង។ ប្រសិនបើនេះជាករណីនៅក្នុងកន្លែងដែលអ្នករស់នៅអ្នកប្រហែលជាចង់លើកទឹកចិត្តរដ្ឋាភិបាលរបស់អ្នកឱ្យធ្វើការអភិវឌ្ឍន៍គោលនយោបាយ សំរាប់ការធ្វើរោគវិនិច្ឆ័យរោគរបេងដោយយោងទៅតាមសិទ្ធិទទួលបានវិទ្យាសាស្ត្រ និងសិទ្ធិសុខភាព។

## តើកុមារគួរធ្វើតេស្តរកជំងឺរបេងយ៉ាងដូចម្តេច?

ការធ្វើរោគវិនិច្ឆ័យអាចជាបញ្ហាប្រឈមច្រើនចំពោះកុមារ ពីព្រោះពួកគេមានបាក់តេរីតិចជាងមនុស្សពេញវ័យនិងអាចមានបញ្ហាក្នុងការក្អកយកកំហាក។ កុមារគួរតែត្រូវបានផ្តល់ឱ្យជាប្រចាំនូវកាំរស្មីX-ray និងអាចត្រូវការវិធីសាស្ត្របន្ថែមទៀតសម្រាប់ការទទួលបានគំរូមួយដែលអាចត្រូវបានធ្វើតេស្តនៅលើ GeneXpert (ហៅថាថ្នាំ gastric aspirate) ។

## ចុះចំពោះការធ្វើរោគវិនិច្ឆ័យជំងឺរបេងស៊ាំនឹងថ្នាំ?

ដើម្បីធ្វើឱ្យការព្យាបាលជំងឺរបេងមានប្រសិទ្ធិភាព គឺជំងឺរបេងរបស់អ្នកគួរតែឆាប់ទទួលបានថ្នាំដែលអ្នកកំពុងព្យាបាល។ វាគឺជាការចាំបាច់ដើម្បីរកឱ្យឃើញឆាប់ ថាតើជំងឺរបេងរបស់អ្នកមានភាពស៊ាំនឹងថ្នាំ(មិនងាយទទួលយក) ចំពោះថ្នាំណាមួយក្នុងការព្យាបាលរបស់អ្នក។ ការធ្វើរោគវិនិច្ឆ័យជំងឺរបេងដែលស៊ាំនឹងថ្នាំ ក៏ត្រូវបានគេហៅថាការធ្វើតេស្តងាយនឹងទទួលថ្នាំ ឬ DST ។ GeneXpert អាចរកឃើញភាពប្រឆាំងទៅនឹងឱសថ rifampicin ។ ការធ្វើតេស្តមួយផ្សេងទៀតដែលហៅថា ការធ្វើការស៊ើបអង្កេត (line probe assay) អាចប្រាប់បានក្នុងរយៈពេល ពីរ បីថ្ងៃ ប្រសិនបើអ្នកជំងឺរបេងមានភាពស៊ាំទៅនឹងថ្នាំដ៏សំខាន់ផ្សេងទៀតរួមទាំង isoniazid, ថ្នាំចាក់ជួរជាទីពីរ (the second-line injectables) (amikacin, capreomycin, kanamycin), and fluoroquinolones (levofloxacin, moxifloxacin)។ ការធ្វើការស៊ើបអង្កេត (Line probe assays) គួរត្រូវមាន។ ប្រសិនបើមិនអាចធ្វើទៅបាន នោះការបណ្តុះវត្ថុរាវ (ដែលចំណាយពេលពីរបីសប្តាហ៍) ក៏គួរត្រូវបានយកមកប្រើបានផងដែរ។

# សិទ្ធិ និងការធ្វើរោគវិនិច្ឆ័យ






## ចុះបើខ្ញុំរស់នៅជាមួយមេរោគអេដស៍ ?

ការធ្វើរោគវិនិច្ឆ័យជំងឺរបេងចំពោះអ្នកដែលមានផ្ទុកមេរោគអេដស៍អាចមានការពិបាកជាងនេះ ពីព្រោះអ្នកផ្ទុកមេរោគអេដស៍អាចមានកម្រិតខុសៗគ្នានៃជំងឺរបេងនៅក្នុងសួតរបស់ពួកគេ ហើយជារឿយៗមានជំងឺរបេងនៅក្រៅសួត (ជំងឺរបេងក្រៅសួត) ។ ម៉ាស៊ីន GeneXpert ជាពិសេស MTB / RIF ឬទឹកថ្នាំពិសេស (Ultra cartridge) មានលក្ខណៈល្អប្រសើរក្នុងការរុករកជំងឺរបេង - រួមទាំងជំងឺរបេងក្រៅសួត - នៅក្នុងខ្លួនអ្នកមានផ្ទុកមេរោគអេដស៍ បានប្រសើរជាងការរុករកជំងឺរបេង ដោយការដាក់កំហាកក្នុងមីក្រូទស្សន៍។

ឧបករណ៍រកជំងឺរបេងបែបថ្មី ដែលគេហៅថា TBLAM គឺជាឧបករណ៍ធ្វើតេស្តបែបថ្មីមួយដែលអាចរកឃើញរោគ របេងនៅក្នុងទឹកនោម។ អង្គការសុខភាពពិភពលោកណែនាំឱ្យធ្វើតេស្ត ដោយប្រើឧបករណ៍ TBLAM គឺអាចប្រើបានតែសំរាប់អ្នកដែលរស់នៅជាមួយមេរោគអេដស៍មានកោសិកា CD4 ≤100 កោសិកា / មីល្លីម៉ែត្រគីប ឬសម្រាប់អ្នកជំងឺដែលមានជំងឺអេដស៍ធ្ងន់ធ្ងរ។ ប្រសិនបើការធ្វើតេស្តដោយប្រើឧបករណ៍ TBLAM មានលទ្ធផលវិជ្ជមាន អ្នកគួរតែចាប់ផ្តើមព្យាបាលភ្លាម ដោយមិនចាំបាច់រង់ចាំការធ្វើតេស្តផ្សេងទៀតនោះឡើយ។ ការធ្វើតេស្តដោយប្រើឧបករណ៍ TBLAM អាចនឹងរកមិនឃើញនូវជំងឺរបេងខ្លះ ដូច្នេះប្រសិនបើការធ្វើតេស្ត ដោយប្រើឧបករណ៍ TBLAM មានលទ្ធផលអវិជ្ជមាន អ្នកប្រហែលជានៅតែមានជំងឺរបេង ហើយជាការចាំបាច់ដែលអ្នកត្រូវធ្វើតាមដានបន្តដោយប្រើម៉ាស៊ីន GeneXpert ។

# សិទ្ធិ និងការធ្វើរោគវិនិច្ឆ័យ



## ចុះបើខ្ញុំមានផ្ទៃពោះ ?

ការមានផ្ទៃពោះគឺជាឱកាសមួយដើម្បីទទួលការថែទាំសុខភាព។ក្នុងករណីខ្លះ ការមានផ្ទៃពោះអាចបង្កើនហានិភ័យនៃការវិវត្តទៅជាជំងឺរបេង។ប្រសិនបើអ្នករស់នៅក្នុងស្ថានភាពដែលមានអត្រាខ្ពស់នៃជំងឺរបេង អ្នកគួរតែសួរគ្រូពេទ្យរបស់អ្នកអំពីការធ្វើតេស្តរកមេរោគរបេង។ដោយសារតែរោគសញ្ញាមិនដំណើរការល្អ ចំពោះស្ត្រីមានផ្ទៃពោះ អ្នកគួរតែស្នើសុំការធ្វើតេស្តជាមួយម៉ាស៊ីន GeneXpert ឬការធ្វើតេស្តសារធាតុរាវយ៉ាងរហ័សជាពិសេស ប្រសិនបើអ្នករស់នៅជាមួយមេរោគអេដស៍។ យោងតាមអង្គការសុខភាពពិភពលោក កាំរស្មី X-ray មិនបង្កឱ្យមានគ្រោះថ្នាក់ខ្លាំងក្លាណាមួយសម្រាប់ទារកដែលកំពុងលូតលាស់របស់អ្នកនោះទេ ដរាបណាគ្រូពេទ្យរបស់អ្នកអនុវត្តន៍ល្អ ដូចជាផ្តល់ឱ្យអ្នកនូវអាវអៀមដែលមានសារជាតិសំណដើម្បីពាក់លើពោះរបស់អ្នក។

## តើខ្ញុំអាចត្រូវបង្ខំឲ្យធ្វើតេស្តដែរឬទេ ?

ការធ្វើតេស្តរកមេរោគរបេងគួរតែត្រូវបានធ្វើឡើងតែជាមួយនឹងការព្រមព្រៀងរបស់អ្នកប៉ុណ្ណោះ។អ្នកផ្តល់សេវាមួយចំនួន ឬនិតិវិធីសម្រាប់អន្តោប្រវេសន៍ តម្រូវឱ្យធ្វើតេស្តរកមេរោគឬជំងឺរបេង។ ទោះជាយ៉ាងណាក៏ដោយការធ្វើតេស្តវិជ្ជមានមិនគួររារាំងអ្នកមិនឱ្យធ្វើការ ឬរស់នៅក្នុងប្រទេសមួយផ្សេងទៀតទេ។ ប្រសិនបើការធ្វើតេស្តរបស់អ្នកបង្ហាញ ថាអ្នកមានមេរោគរបេង ឬជំងឺរបេង អ្នកគួរតែទទួលបានការព្យាបាល។